បានទទួល/22-06-16

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

[redacted]

សាលាដំបូងខេត្តសៀមរាប

## សម្រេចសាលក្រមព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌលេខ ១៦ -ក-
ទី ២៨ ខែ មេសា ឆ្នាំ ២០១៦

រឿងព្រហ្មទណ្ឌលេខ ១០៦៩
ទី ២១ ខែ តុលា ឆ្នាំ២០១៥

រឿងជំនុំជម្រះលេខ ៥១
ទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦

តាមសាលក្រមព្រហ្មទណ្ឌលេខ ១៦ -ក- ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តសៀមរាប ដែលបានបើកសវនាការជាសាធារណៈ ។

-កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ ។

-កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ។

*ជំនុំជម្រះលើជនជាប់ចោទ :*

១/-ឈ្មោះ[redacted]រតនា ភេទប្រុស ឆ្នាំកំណើត ១៩៩៤ ជនជាតិខ្មែរ កើតនៅភូមិចុងឃ្លៀស ឃុំចុងឃ្លៀស ស្រុកសៀមរាប ខេត្តសៀមរាប ។ អាសយដ្ឋានមុនពេលចាប់ខ្លួន[redacted] សង្កាត់ចុងឃ្លៀស ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ[redacted] -រ- ម្ដាយឈ្មោះ ជូរ [redacted] -រ- នៅលីវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

២/-ឈ្មោះ: [redacted]ពិសិដ្ឋ ភេទប្រុស ឆ្នាំកំណើត ១៩៩៨ ជនជាតិខ្មែរ កើតនៅភូមិ ត្រពាំងស្វាយ ឃុំត្រពាំងស្វាយ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ អាសយដ្ឋានមុនពេលចាប់ខ្លួនភូមិចុង [redacted] ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ: [redacted] -រ- ម្ដាយឈ្មោះ:[redacted] -រ- នៅលីវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

៣/-ឈ្មោះ: [redacted] សារ៉ាង ភេទប្រុស ឆ្នាំកំណើត ១៩៩៨ ជនជាតិខ្មែរ កើតនៅភូមិជន្លង់ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប ។ អាសយដ្ឋានមុនពេលចា[redacted] សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ:[redacted] -រ- ម្ដាយពុំស្គាល់ឈ្មោះ -ស- នៅលីវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

៤/-ឈ្មោះ:[redacted]អាណា ភេទប្រុស ឆ្នាំកំណើត ១៩៩១ ជនជាតិខ្មែរ កើតនៅស្រុកស្អាង ខេត្តកណ្ដាល។ អាសយដ្ឋានមុនពេលចាប់ខ្លួន[redacted] ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ: [redacted] -រ- ម្ដាយឈ្មោះ: [redacted] -រ- ប្រពន្ធឈ្មោះ:[redacted]ណា មានកូន ២ នាក់ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

៥/-ឈ្មោះ: [redacted]សេត ភេទប្រុស ឆ្នាំកំណើត ១៩៨៨ ជនជាតិខ្មែរ កើតនៅភូមិ[illegible]ប្រុស ឃុំ

Scanned by CamScanner

កណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ អាសយដ្ឋានមុនពេលចាប់ខ្លួន [redacted] កណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -ស- ម្ដាយឈ្មោះ [redacted] -ស- នៅលើវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

៦/-ឈ្មោះ [redacted] វិច្ឆិកា ភេទប្រុស ឆ្នាំកំណើត ១៩៩២ ជនជាតិខ្មែរ កើតនៅភូមិជន្លង់ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប ។ អាសយដ្ឋានមុនពេល[redacted] សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -រ- ម្ដាយ ឈ្មោះ [redacted] -រ- នៅលើវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

៧/-ឈ្មោះ [redacted] មុំ ភេទស្រី ឆ្នាំកំណើត ១៩៩៣ ជនជាតិខ្មែរ កើតនៅភូមិបឹងក្រោម ឃុំអាទាវ ស្រុកលើកដែក ខេត្តកណ្ដាល។ អាសយដ្ឋានមុនពេលចាប់ខ្លួ[redacted]លា កំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -ស- ម្ដាយឈ្មោះ [redacted] -ស- នៅលើវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

៨/-ឈ្មោះ [redacted] សុខុម ហៅ បារាំង ភេទប្រុស ឆ្នាំកំណើត ១៩៩៥ ជនជាតិខ្មែរ កើតនៅ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ អាសយដ្ឋានបច្ចុប្បន្ន[redacted] ក្រុង សៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -ស- ម្ដាយឈ្មោះ [redacted] -រ- នៅលើវ ( គេចខ្លួន ) ។

ជាប់ចោទពីបទ : ជួញដូរ និងចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែ តុលា ឆ្នាំ២០១៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៣ និង ៤ និងមាត្រា ៤២ កថាខណ្ឌ ២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

តាមដីកាដំណោះស្រាយលេខ ២៩ ពស.ព្រស/២០១៦ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តសៀមរាប ។

មានលោកស្រី [redacted]នារី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted]សារ៉ាំង ( វត្តមាន ) ។

## ហេតុដូច្នេះសាលាដំបូងខេត្តសៀមរាប
## វិនិច្ឆ័យសេចក្ដី

១/-ផ្ដន្ទាទោស :

ក/-ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស ឆ្នាំកំណើត ១៩៩៨ ជនជាតិខ្មែរ កើតនៅភូមិក្រពាំងស្វាយ ឃុំក្រពាំងស្វាយ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ អាសយដ្ឋានមុនពេលចាប់ខ្លួនភូមិជន្លង់

Scanned by CamScanner

[redacted] ក្រុងសៀមរាប ខេត្តសៀមរាប។ ឪពុកឈ្មោះ [redacted] -រ- ម្តាយឈ្មោះ [redacted] -រ- នៅលីវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

ដាក់ពន្ធនាគារកំណត់ ០២ ( ពីរ ) ឆ្នាំ ។

ខ/-ឈ្មោះ [redacted] អាណា ភេទប្រុស ឆ្នាំកំណើត ១៩៩១ ជនជាតិខ្មែរ កើតនៅស្រុកស្អាង ខេត្តកណ្តាល។ អាសយដ្ឋានមុនពេលចាប់ខ្លួន[redacted] ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -រ- ម្តាយឈ្មោះ[redacted] -រ- ប្រពន្ធឈ្មោះ ហាន់ [redacted]មានកូន ២ នាក់ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

ដាក់ពន្ធនាគារកំណត់ ០៣ ( បី ) ឆ្នាំ ។

គ/-ឈ្មោះ [redacted]សុខុម ហៅ បារាំង ភេទប្រុស ឆ្នាំកំណើត ១៩៩៥ ជនជាតិខ្មែរ កើតនៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ អាសយដ្ឋានបច្ចុប្បន្ន[redacted]ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -ស- ម្តាយឈ្មោះ [redacted] -រ- នៅលីវ ។ ( គេចខ្លួន ) ។

ដាក់ពន្ធនាគារកំណត់ ០៣ ( បី ) ឆ្នាំ ។

ពីបទ : ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កឋាខណ្ឌ ៣ និង ៤ និងមាត្រា ៤៥ កឋាខណ្ឌ ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ឃ/-ឈ្មោះ [redacted]វិច្ឆិកា ភេទប្រុស ឆ្នាំកំណើត ១៩៩២ ជនជាតិខ្មែរ កើតនៅភូមិជន្លង់ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប ។ អាសយដ្ឋានមុនពេលចាប់[redacted] ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -រ- ម្តាយឈ្មោះ [redacted] -រ- នៅលីវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

ង/-ឈ្មោះ [redacted] មុំ ភេទស្រី ឆ្នាំកំណើត ១៩៩៣ ជនជាតិខ្មែរ កើតនៅភូមិបឹងក្រោម ឃុំអាទាវ ស្រុកលើកដែក ខេត្តកណ្តាល។ អាសយដ្ឋានមុនពេលចាប់[redacted] កំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -ស- ម្តាយឈ្មោះ [redacted] -ស- នៅលីវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

ច/-ឈ្មោះ [redacted]រតនា ភេទប្រុស ឆ្នាំកំណើត ១៩៩៤ ជនជាតិខ្មែរ កើតនៅភូមិចុងឃ្លៀស ឃុំចុងឃ្លៀស ស្រុកសៀមរាប ខេត្តសៀមរាប ។ អាសយដ្ឋានមុនពេលចាប់ខ្លួនភូមិចុងឃ្លៀស [redacted] ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -រ- ម្តាយឈ្មោះ ជុំ

Scanned by CamScanner

មុំ -រ- នៅលីវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

ឆ/-ឈ្មោះ [redacted]សេត ភេទប្រុស ឆ្នាំកំណើត ១៩៨៨ ជនជាតិខ្មែរ កើតនៅភូមិច្រេស ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ អាសយដ្ឋានមុនពេលចាប់ខ្លួន[redacted] កណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -ស- ម្ដាយឈ្មោះ [redacted] -ស- នៅលីវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

ដាក់ពន្ធនាគារម្នាក់ៗកំណត់ ០២ ( ពីរ ) ឆ្នាំ ដោយទោសនេះឲ្យអនុវត្តក្នុងពន្ធនាគាររយៈពេល ០១ ( មួយ ) ឆ្នាំ ទោសនៅសល់ពីនេះឲ្យព្យួរការអនុវត្តជម្មតា តាមមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ ។

ជ/-ឈ្មោះ [redacted]សារ៉ាង ភេទប្រុស ឆ្នាំកំណើត ១៩៩៨ ជនជាតិខ្មែរ កើតនៅភូមិជន្លង់ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប ។ អាសយដ្ឋានមុនពេល[redacted] សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ [redacted] -រ- ម្ដាយពុំស្គាល់ឈ្មោះ -ស- នៅលីវ ។ ទោសពីមុន គ្មាន ។

ឃុំខ្លួនថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ។

ដាក់ពន្ធនាគារកំណត់ ០១ ( មួយ ) ឆ្នាំ ដោយទោសនេះឲ្យអនុវត្តក្នុងពន្ធនាគាររយៈពេល ០៨ (ប្រាំបី) ខែ ទោសនៅសល់ពីនេះឲ្យព្យួរការអនុវត្តជម្មតា តាមមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ ។

ពីបទ : ចាត់ចែងឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៤២ កឋាខណ្ឌ ១ និង២ និងមាត្រា ៤៥ កឋាខណ្ឌ ១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/-ឲ្យឈ្មោះ[redacted]រិទ្ធិកា , ឈ្មោះ [redacted]សេត , ឈ្មោះ [redacted]រតនា , ឈ្មោះ[redacted] និង ឈ្មោះ [redacted]សារ៉ាង រួចខ្លួន ។

ពីបទ : ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ អង្គហេតុចោទប្រកាន់ប្រព្រឹត្តនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៤០ កឋាខណ្ឌ ៣ និង ៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣/- ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted]សុខុម ហៅ បារាំង និងយកមកឃុំខ្លួនក្នុងពន្ធនាគារ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤/-រឹបអូសថ្នាំញៀនម្សៅគ្រីមពណ៌សថ្លាចំនួនមួយកញ្ចប់ ទូរស័ព្ទដៃចំនួនប្រាំគ្រឿង (ម៉ាក ណូគាពណ៌ក្រហម-ខ្មៅមួយគ្រឿង , ម៉ាកណូគា ពណ៌ខ្មៅមួយគ្រឿង , ម៉ាក[illegible] ពណ៌

Scanned by CamScanner

ខ្មៅមួយគ្រឿង ,ម៉ាកណូគាចុចពិលពណ៌ខៀវមួយគ្រឿង , ម៉ាកណូគាពណ៌ទឹកក្រូចមួយគ្រឿង ) និងឧបករណ៍សម្ភារៈប្រើប្រាស់ថ្នាំញៀនមួយចំនួន ។

- វត្ថុចាប់យកទាំងនេះត្រូវបានរក្សាទុកនៅសាលាដំបូងខេត្តសៀមរាប តាមដីកាបង្គាប់ឲ្យរក្សាទុកវត្ថុចាប់យកលេខ ៣៧៧ វត/ព្រទ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥ ។

៣/-សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ពិសិដ្ឋ ឈ្មោះ[redacted] អាណា ឈ្មោះ [redacted]វិច្ឆិកា ឈ្មោះ [redacted]សេត ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] មុំ និងឈ្មោះ [redacted] សារ៉ាង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុខុម ។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ៕

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
*សៀមរាប ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦*
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

Scanned by CamScanner